ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០១៣

លេខៈ ៨

ឆ្នាំ២០១៦

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០១៣

# អារម្ភកថា

ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៣នៅព្រះរាជាណាចក្រកម្ពុជា ទទួលបានជោគជ័យប្រកបដោយលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ ទោះបីត្រូវបានអនុវត្តនៅក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកនៅបន្តប្រឈមនឹងភាពមិនច្បាស់លាស់បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុ និងវិបត្តិបំណុលដែលកើតមានឡើងនាឆ្នាំកន្លងមក គ្រោះធម្មជាតិ និងសម្ពាធចំណាយថវិកាក្នុងអំឡុង និងក្រោយការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ យ៉ាងណាក់ដោយ។

ដើម្បីជំនះបាននូវឥទ្ធិពលអវិជ្ជមានពីខាងក្រៅ និងការប្រឈមទាំងនោះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តគោលនយោបាយ និងវិធានការប្រកបដោយប្រសិទ្ធភាព ហ្មត់ចត់ ទន់ភ្លន់ និងទាន់ពេលវេលា ជាពិសេសឈរលើទស្សនៈនៃការដឹកនាំគ្រប់គ្រងសភាពការណ៍តាមបែបចល័តដែលធ្វើឱ្យរាជរដ្ឋាភិបាលសម្រេចបាននូវការអភិវឌ្ឍលើវិស័យសំខាន់ៗ និងកំណើនសេដ្ឋកិច្ចខ្ពស់ជាងការគ្រោងទុកនៅក្នុងច្បាប់ថវិកាដើមឆ្នាំ២០១៣។ ជាសក្ខីភាព សមិទ្ធផលរបស់រាជរដ្ឋាភិបាលទាំងនេះបានឆ្លុះបញ្ចាំងតាមរយៈចំណូលថវិកាថ្នាក់ជាតិដែលអនុវត្តបានប្រមាណ **២១,៧៦%** នៃផ.ស.ស[១] គឺបានកើនខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **១០,៥%** ហើយបានកើនឡើង **៨,៨%** ធៀបទៅនឹងការអនុវត្តន៍ឆ្នាំ២០១២។ ចំណាយថវិកាថ្នាក់ជាតិសរុបអនុវត្តបានប្រមាណ **២១,៣២%** នៃផ.ស.ស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៨,២%** ហើយបានកើនឡើង **៨,២%** ធៀបទៅនឹងការអនុវត្តន៍ឆ្នាំ២០១២។ ការអនុវត្តចំណូល និងចំណាយនេះបានធ្វើឱ្យមានការសន្សំអតិរេកថវិកាចំនួន **២៧០ ១៥០,៧**លានរៀល។ ចំពោះថវិការាជធានី-ខេត្ត ចំណូលអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន **៣៨,៥%** រីឯចំណាយអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន**១៥,២%**។ ការអនុវត្តចំណូល និងចំណាយនេះបានធ្វើឱ្យមានអតិរេកថវិកាចំនួន **១២១ ២៩៩,0**លានរៀល។

រាជរដ្ឋាភិបាលបានរក្សាយ៉ាងខ្ជាប់ខ្ជួននូវវិន័យថវិកាដោយត្បិតត្បៀតចំណាយចរន្ត ដើម្បីរក្សាអតិរេកចរន្តសម្រាប់ការវិនិយោគទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង និងផ្នែកទន់ ចំណាយលើការវិនិយោគ និងចំណាយលើកិច្ចការពារអធិបតេយ្យភាព ដែលជាមូលដ្ឋានសម្រាប់ពង្រឹងកិច្ចការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ ព្រមទាំងពង្រីកសកម្មភាពសេដ្ឋកិច្ច ដើម្បីបង្កើនចំណូល និងលើកកម្ពស់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ តាមរយៈការខិតខំប្រឹងប្រែងនេះ សេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០១៣ បន្តកើនឡើងយ៉ាងរឹងមាំ ដោយមានកំណើន **៧,៤%** ធៀបនឹងការព្យាករណ៍ប្រមាណ **៧%** ។ លទ្ធផលនៃកំណើនសេដ្ឋកិច្ចខាងលើបានធ្វើឱ្យចំណូលមធ្យមសម្រាប់មនុស្សម្នាក់ៗបានកើនឡើងពី **៩៧៣** ដុល្លារអាមេរិក នៅឆ្នាំ២០១២ ដល់ **១ ០៤៣** ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៣ ព្រមទាំងធ្វើឱ្យសម្រេចបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្របានជាង **១%** ក្នុងមួយឆ្នាំ ។

---

[១] សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤។

លទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីភាពប្រសើរឡើងនៃកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ។ រាជរដ្ឋាភិបាលនៅតែបន្តខិតខំអភិវឌ្ឍសេដ្ឋកិច្ច និងអនុវត្តកម្មវិធីកំណែទម្រង់ ដោយប្រកាន់ខ្ជាប់នូវទិសស្លោក "**កំណែទម្រង់ គឺជាការស្លាប់រស់របស់រាជរដ្ឋាភិបាលកម្ពុជា**" ហើយគឺជាការងារប្រចាំថ្ងៃសម្រាប់ការបន្តកែលម្អ ពង្រឹង និងបង្កើនសមត្ថភាព និងសក្តានុពលដើម្បីសម្រេចបានចីរភាព និងបរិយាប័ន្ននៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ដូច្នេះ គឺជាការត្រឹមត្រូវណាស់ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រសិទ្ធនាមថវិកាឆ្នាំ២០១៣ ថាជាថវិកាសម្រាប់ **«បន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ មូលដ្ឋានសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គមប្រកបដោយគុណភាព តាមរយៈការបន្តរក្សាស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបន្តជំរុញការអភិវឌ្ឍវិស័យគន្លឹះ ពិសេសវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មធុនស្រាល និងទេសចរណ៍ និងការអនុវត្តកម្មវិធីកំណែទម្រង់លើគ្រប់វិស័យឲ្យកាន់តែស៊ីជម្រៅ»**។

ជាមួយនឹងសមិទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣នេះ បានសបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្ត និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការរក្សាបាននូវសុខសន្តិភាព ស្ថិរភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម ឯករាជ្យភាព ឯកភាពជាតិ បូរណភាពទឹកដី ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងជំរុញសកម្មភាពសេដ្ឋកិច្ច កសាងហេដ្ឋារចនាសម្ព័ន្ធ បង្កើនកាលានុវត្តភាពការងារ និងអភិវឌ្ឍធនធានមនុស្ស សំដៅលើកកម្ពស់ជីវភាព ក៏ដូចជាកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស ដើម្បីក្លាយជាប្រទេសដែលមានការអភិវឌ្ឍជឿនលឿនតាមផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋានអង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះ លើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០១៣ របស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ដោយការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់

មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្ដានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្រ២០១២-២០១៦ របស់ខ្លួន។ ចំពោះមុខអាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច គោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរ ដល់អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់(GIZ) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ព្រមទាំងដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានាដែលបានផ្ដល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា សកម្មភាពទាំងនេះនឹងនៅតែបន្តយ៉ាងសកម្ម ដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រឡាញ់នៃយើងទាំងអស់គ្នា។

រាជធានីភ្នំពេញ. ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦

**អគ្គសវនករ**

**សោម គីមសួគ៌**

# មាតិកា


**សេចក្តីសង្ខេប** ........ ១

**១. សេចក្តីផ្តើម** ........ ៣

**១.១.លក្ខណៈទូទៅ** ........ ៣

**១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម** ........ ៣

**១.៣. គោលបំណងនៃការផ្សព្វផ្សាយ** ........ ៤

**២. ការគ្រប់គ្រងថវិកា** ........ ៤

**២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា** ........ ៤

**២.២.កិច្ចប្រតិបត្តិការថវិកា** ........ ៥

**៣. លទ្ធផលសវនកម្ម** ........ ៦

**៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ** ........ ៦

៣.១.១. ការចេញវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមដល់ក្រុមហ៊ុន សហគ្រាស ៦

៣.១.២. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ ........ ៧

៣.១.៣. ការធ្វើសវនកម្មពុំទាន់មានវិធីសាស្រ្តសវនកម្មជាក់លាក់........ ៨

៣.១.៤. ការរក្សាតួលេខសមតុល្យចុងឆ្នាំ២០១៣........ ៨

៣.១.៥. ការកំណត់តម្លៃគិតពន្ធលើទំនិញមួយចំនួន........ ៩

៣.១.៦. ការគ្រប់គ្រងអាជីវកម្មឆ្នោត និងល្បែងភ្នាល់ ........ ១០

៣.១.៧. ការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច........ ១១

៣.១.៨. ការប្រមូលចំណូលពីការអនុញ្ញាតផ្សព្វផ្សាយពាណិជ្ជកម្ម........ ១២

៣.១.៩. ការអនុវត្តចំណាយចរន្តសម្រាប់គម្រោងវិនិយោគ........ ១៣

៣.១.១០. ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈមិនស្របតាមផែនការ ........ ១៤

៣.១.១១. ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ........ ១៤

**៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ** ........ ១៦

៣.២.១. ការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ........ ១៦

៣.២.២. ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសំណង់.. ១៧

៣.២.៣. ការចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារ បរិក្ខារ និងគ្រឿងចក្រសំណង់........ ១៧

**៤.ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តន៍អនុសាសន៍សវនកម្ម** ........ ១៨

**៥.សេចក្តីសន្និដ្ឋាន** ........ ២២

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០១៣

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបាន បង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧ នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

ទោះបីកម្ពុជាបានជួបប្រទះនូវគ្រោះទឹកជំនន់ ស្ថានភាពសេដ្ឋកិច្ចនៅមានលក្ខណៈផុយស្រួយ និងមានហានិភ័យខ្ពស់យ៉ាងណាក្តី ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច **៧,៤%** ធៀបនឹងការព្យាករណ៍ដែលបានរំពឹងទុកប្រមាណ **៧%** ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រជាង **១%** ក្នុងមួយឆ្នាំដែលជាលទ្ធផលគួរឱ្យកត់សម្គាល់។

សម្រាប់ការិយបរិច្ឆេទ២០១៣ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ការអនុវត្តចំណូលសម្រេចបានចំនួន **១៣ ៣៦០ ៥៣៤** លានរៀល ស្មើនឹង**២១,៧៦%** នៃ ផ.ស.ស គឺបានកើនខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **១០,៥%** ហើយបានកើនឡើង **៨,៨%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១២។ ទាំងនេះឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលតាមរយៈការកែលម្អគោលនយោបាយសារពើពន្ធ ការបង្កើនប្រសិទ្ធភាពនៃរដ្ឋបាលសារពើពន្ធ និងអភិបាលកិច្ចល្អក្នុងការប្រមូលចំណូលតាមផ្នែកនីមួយៗ ដូចជាចំណូលគយ និងរដ្ឋាករ ចំណូលពន្ធដារ និងចំណូលមិនមែនសារពើពន្ធ។ ក្នុងនោះចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អ តាមរយៈការដាក់ចេញនូវគោលនយោបាយ និងវិធាននៃការប្រមូលចំណូលមួយចំនួន ហើយចំណូលពន្ធដារក៏ទទួលបានលទ្ធផលល្អប្រសើរ ដោយមានការកែលម្អគោលនយោបាយសារពើពន្ធ និងពង្រឹងរដ្ឋបាលសារពើពន្ធ ក្នុងគោលដៅបង្កើនចំណូលពន្ធ និងកាត់បន្ថយអំពើគេចវេះពន្ធ។ ទោះបីជាចំណូលមិនមែនសារពើពន្ធសម្រេចបានលទ្ធផលល្អ តែបញ្ហាប្រឈមនៅតែកើតមាន ប៉ុន្តែរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការមួយចំនួន រួមមាន (១)ពង្រឹងការប្រមូលចំណូល ដោយប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ (២)ជំរុញក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងក្រោមជាតិអនុវត្តប្រកាសរួម ស្តីពីការផ្តល់សេវាសាធារណៈ (៣) បន្តពង្រឹង និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈរបស់រដ្ឋ។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានប្រភេទចំណូលមួយចំនួនទៀតដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀតមានជាអាទិ៍៖ ការចេញវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមដល់ក្រុមហ៊ុន-សហគ្រាស ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ ការកំណត់តម្លៃគិតពន្ធលើទំនិញមួយចំនួន ការគ្រប់គ្រងអាជីវកម្មឆ្នោតនិងល្បែងភ្នាល់ ការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ការទៅបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស ការប្រមូលចំណូលពីការអនុញ្ញាតផ្សព្វផ្សាយពាណិជ្ជកម្ម និងការរក្សាតួលេខសមតុល្យចុងឆ្នាំ២០១៣។

ការអនុវត្តចំណាយសម្រេចបានចំនួន **១៣ ០៩០ ៣៨៣,៣**លានរៀល ស្មើនឹង **២១,៣២%** នៃ ផ.ស.ស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៨,២%** ហើយបានកើនឡើង **៨,២%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១២។ ការអនុវត្តចំណាយសម្រេចបានលទ្ធផលគួរកត់សម្គាល់តាមរយៈ (១)ការពង្រឹងការអនុវត្តកម្មវិធីចំណូលចំណាយថវិកា (២)ការពន្លឿនការអនុវត្តនីតិវិធីចំណាយឱ្យចំទិសដៅ និងទាន់ពេលវេលា (៣)ការអនុវត្តចំណាយដោយម៉ឺងម៉ាត់ និងហ្មត់ចត់តាមបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ជាពិសេសជំរុញការអនុវត្តលទ្ធកម្មសាធារណៈឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព ភាពយុត្តិធម៌ និងប្រសិទ្ធភាពជាងមុន។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តចំណាយថវិកានេះក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដូចជា៖ ការអនុវត្តចំណាយចរន្តសម្រាប់គម្រោងវិនិយោគ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះសម្រេចបានចំនួន **៤ ៣០៦ ០៨៣,៩** លានរៀល ស្មើនឹង**១៣៦,៩%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន **៣ ១៤៦ ០០០** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន **១ ១៦០ ០៨៣,៩** លានរៀល។

### ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ការអនុវត្តចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តសម្រេចបានចំនួន **៧២០ ៣៥៦,៦** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ចំនួន**៣៨,៥%** និងការអនុវត្តចំណាយសម្រេចបានចំនួន **៥៩៩ ០៥៧,៦**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ចំនួន**១៥,២%**។ រីឯការអនុវត្តចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រេចបាន **៧៥ ៦៩២,៨** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ចំនួន **៥,៨%** និងការអនុវត្តចំណាយសម្រេចបាន **៧២ ១៧០,៣** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ចំនួន **១០,១%**។ ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា៖ ការប្រមូលពន្ធអចលនទ្រព្យ ការគ្រប់គ្រងអ្នកជាប់ពន្ធតាមរបបម៉ៅការ ការប្រមូលពន្ធតាមរបបម៉ៅការ ការចំណាយតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ការតាមដានការងារសំណង់ ការចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារ បរិក្ខារ និងគ្រឿងចក្រសំណង់។

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ គឺរហូតមកដល់បច្ចុប្បន្ន ទោះបីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្លាប់បានចេញប្រកាស និងសារាចរណែនាំច្រើនរំលឹកជាញឹកញាប់យ៉ាងណាក៏ដោយក៏ក្រសួង-ស្ថាប័ន និងសាលារាជធានី-ខេត្តមួយចំនួននៅតែមានភាពយឺតយ៉ាវ និងខកខានក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិ។

## ១. សេចក្តីផ្តើម

### ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនីប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជនសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាលដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

### ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០១៣ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង-ស្ថាប័នរដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ព្រមទាំងបានធ្វើរបាយការណ៍សរុបមានចំនួន៦៩១ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ ដោយឡែកសម្រាប់ការិយបរិច្ឆេទ២០១៣ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបមានចំនួន៩៣ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន-សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១៣នេះ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/ ១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៣ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្ត ចំណូល-ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី-ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

### ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០១២ | ២០១៣ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *១* | *២* | *៣* | *៤ = (៣/២)* |
| **I. សរុបចំណូល** | **១២ ២៨៤ ២៨៦,៦** | **១២ ០៩៥ ០៧៣,៣** | **១៣ ៣៦០ ៥៣៤** | **១១០,៥%** |
| -ចំណូលចរន្ត | ៧ ៨៩២ ៦៧៩,៩ | ៨ ៤៧៣ ៧៧៨,៣ | ៨ ៧០៥ ៦០៥,៧ | ១០២,៧% |
| -ចំណូលមូលធនក្នុងប្រទេស | ២៥០ ៨៥១,៧ | ៨២ ០០០ | ៦៨ ១៦៩,៧ | ៨៣,១% |
| -មូលនិធិទ្រទ្រង់ថវិកា | ១១៨ ១២០,៥ | ២២២ ០២១ | ២៨០ ६៧៤,៧ | ១២៦,៤% |
| -ប្រើប្រាស់ប្រាក់បញ្ញើរាជរដ្ឋាភិបាល | - | ១៧១ ២៧៤ | - | - |
| -ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ០២២ ៦៣៤,៥ | ៣ ១៤៦ ០០០ | ៤ ៣០៦ ០៨៣,៩ | ១៣៦,៩% |
| **II. សរុបចំណាយ** | **១២ ០៩៧ ២៦៧,៦** | **១២ ០៩៥ ០៧៣,៣** | **១៣ ០៩០ ៣៨៣,៣** | **១០៨,២%** |
| -ចំណាយចរន្ត | ៦ ៦៧៧ ៣២៧,៣ | ៧ ២១២ ៥៧៣ | ៧ ២៨២ ២៥១ | ១០១% |
| -ចំណាយមូលធន | ១ ៣៩៧ ៣០៥,៨ | ១ ៧៣៦ ៥០០ | ១ ៥០២ ០៤៨,៤ | ៨៦,៥% |
| -ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ០២២ ៦៣៤,៥ | ៣ ១៤៦ ០០០ | ៤ ៣០៦ ០៨៣,៩ | ១៣៦,៩% |

### ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

#### ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០១២ | ២០១៣ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *១* | *២* | *៣* | *៤ = (៣/២)* |
| **I. សរុបចំណូល** | **៧៦២ ៣៣៨** | **៥២០ ២២១** | **៧២០ ៣៥៦,៦** | **១៣៨,៥%** |
| -ចំណូលចរន្ត | ៤៩២ ៦៩២ | ៤៣១ ៩៣៥ | ៥២៥ ០៩៩ | ១២១,៦% |
| •ចំណូលសារពើពន្ធ | ៤៦៥ ២៤២,៥ | ៤០៨ ៧២៧ | ៥០១ ១៩៦,៩ | ១២២,៦% |
| •ចំណូលមិនមែនសារពើពន្ធ | ២៧ ៤៤៩,៥ | ២៣ ២០៨ | ២៣ ៩០២,១ | ១០៣% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ២៦៩ ६៤៦ | ៨៨ ២៨៦ | ១៩៥ ២៥៧,៦ | ២២១,២% |
| -ឧបត្ថម្ភសម្រាប់មូលនិធិសង្កាត់ចំណុះរាជធានី | - | ១៨ ០១៦ | ១៣ ២៦៧,៦ | ៧៣,៦% |
| **II. សរុបចំណាយ** | **៥៧៨ ១២១** | **៥២០ ២២១** | **៥៩៩ ០៥៧,៦** | **១១៥,២%** |
| -ចំណាយចរន្ត | ៤៥០ ២៣៧,៧ | ៣៨៤ ៧៩៨ | ៤៥៦ ៩៩៨,៧ | ១១៨,៨% |
| -ចំណាយមូលធន | ១២៧ ៨៨៣,៣ | ១១៧ ៤០៧ | ១២៨ ៧៩១,៣ | ១០៩,៧% |
| -ចំណាយសង្កាត់ចំណុះរាជធានី | - | ១៨ ០១៦ | ១៣ ២៦៧,៦ | ៧៣,៦% |

ខ២/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ២០១៣ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *២* | *៣* | *៤ = (៣/២)* |
| **I. សរុបចំណូល** | **៨០ ៣២១** | **៧៥ ៦៩២,៨** | **៩៤,២%** |
| -ចំណូលចរន្ត | ១ ០៥០ | ១ ៤៤២,៣ | ១៣៧,៤% |
| •ចំណូលមិនមែនសារពើពន្ធ | ១ ០៥០ | ១ ៤៤២,៣ | ១៣៧,៤% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ (ក្នុងនោះ ឧបត្ថម្ភ | ៧៩ ២៧១ | ៧៤ ២៥០,៥ | ៩៣,៧% |
| សម្រាប់មូលនិធិសង្កាត់ចំណុះក្រុង) | ២០ ៨៦៦ | ១៥ ៨១៤ | ៧៥,៨% |
| **II. សរុបចំណាយ** | **៨០ ៣២១** | **៧២ ១៧០ ,៣** | **៨៩,៩%** |
| -ចំណាយចរន្ត | ៥៩ ៤៥៥ | ៥៦ ៣៥៦,៣ | ៩៤,៨% |
| -ចំណាយសង្កាត់ចំណុះក្រុង | ២០ ៨៦៦ | ១៥ ៨១៤ | ៧៥,៨% |

# ៣. លទ្ធផលសវនកម្ម

## ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១. ការចេញវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមដល់ក្រុមហ៊ុន សហគ្រាស

ប្រកាសលេខ៩៧០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តារាងឧបសម្ព័ន្ធII អគ្គនាយកដ្ឋានពន្ធដារ ត្រង់ចំណុចទី១ "ស្តីពីការចុះបញ្ជីសហគ្រាស ត្រូវមានសន្លឹកប័ណ្ណ ប៉ាតង់ប្រចាំឆ្នាំ សំណុំឯកសារចុះបញ្ជី រួមទាំងសលាកប័ត្រព័ត៌មាន វិញ្ញាបនបត្រចុះបញ្ជី អាករលើតម្លៃបន្ថែម ដែលមានរយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) ពី០៧ ទៅ ១០ថ្ងៃ"។

តាមការធ្វើតេស្តលើសំណុំឯកសារស្នើសុំចុះបញ្ជីចំនួន១០៣សហគ្រាស នៅរដ្ឋបាលសារពើពន្ធ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារបានចេញវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមដែលមានរយៈពេលផ្តល់សេវាលើសពី១០ថ្ងៃ ដល់សហគ្រាសទាំងនោះ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំអគ្គនាយកដ្ឋានពន្ធដារឲ្យផ្តល់វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមដល់សហគ្រាសឲ្យបានទាន់ពេលវេលា និងស្របតាមប្រកាសលេខ ៩៧០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ ដែលមានជាធរមាន។

ឆ្លើយតបចំពោះការលើកឡើងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថា ការចេញវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមលើសពីរយៈពេល១០ថ្ងៃ ដោយសារមូលហេតុមួយចំនួនគឺ សហគ្រាសមិនបានបំពេញតាមលក្ខខណ្ឌ និងផ្តល់ឯកសារគ្រប់គ្រាន់ ព័ត៌មានរបស់សហគ្រាស ដូចជាអាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនងមិនច្បាស់លាស់ និងមិនអាចទាក់ទងក្រុមហ៊ុន ដើម្បីបញ្ជាក់ព័ត៌មានបន្ថែមបាន។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ

និងការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែឆាប់រហ័សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំប្រកាសថ្មីស្តីពីការចុះបញ្ជីពន្ធដារដែលប្រកាសនេះនឹងជួយសម្រួលដល់អ្នកជាប់ពន្ធដោយកាត់បន្ថយនីតិវិធី និងឯកសារតម្រូវដែលមិនចាំបាច់មួយចំនួនធំ។

ផ្អែកតាមការបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.២.ការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ

ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ផ្អែកទី៣ រដ្ឋបាលសារពើពន្ធ ត្រង់មាត្រា៩៨ បានចែងថា "អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ ..." និងមាត្រា១១៦ ចំណុច៣ បានចែងថា "ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឲ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ នោះអ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ..."។

តាមការធ្វើសវនកម្មលើសំណុំឯកសារ នៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាស លើក្រុមហ៊ុន-សហគ្រាសជាប់ពន្ធចំនួន៤៩ ក្នុងការិយបរិច្ឆេទ២០១៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានក្រុមហ៊ុន-សហគ្រាសជាប់ពន្ធចំនួន២៣ (ក្រុមហ៊ុន-សហគ្រាសចំនួន៦ ស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធធំ និងចំនួន១៧ ស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម) មិនបានកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីគណនេយ្យ និងលិខិតយុត្តិការឲ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ដែលជាហេតុនាំឲ្យរងនូវការកំណត់ពន្ធឡើងវិញជាឯកតោភាគីពីរដ្ឋបាលសាពើពន្ធ។ ការមិនបានកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីគណនេយ្យ និងលិខិតយុត្តិការឲ្យបានត្រឹមត្រូវ អាចនាំឲ្យការកំណត់ពន្ធឡើងវិញរបស់រដ្ឋបាលសារពើពន្ធពុំទាន់សមស្របតាមសកម្មភាពអាជីវកម្មជាក់ស្តែង និងច្បាស់លាស់។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំឲ្យអគ្គនាយកដ្ឋានពន្ធដារចាត់វិធានការម៉ឺងម៉ាត់ចំពោះអ្នកជាប់ពន្ធដែលមិនបានកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីគណនេយ្យ និងលិខិតយុត្តិការឲ្យបានត្រឹមត្រូវស្របតាមច្បាប់ស្តីពីសារពើពន្ធ។

ឆ្លើយតបចំពោះការលើកឡើងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងចាត់វិធានការតាមការកំណត់របស់ច្បាប់ឱ្យកាន់តែម៉ឺងម៉ាត់ថែមទៀតចំពោះក្រុមហ៊ុនណាដែលមិនបានកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវ។ ជាមួយគ្នានេះ ក្រសួងនឹងធ្វើការបណ្តុះបណ្តាលអប់រំសហគ្រាសតូចៗនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌឱ្យបានជ្រួតជ្រាបកាន់តែទូលំទូលាយអំពីកាតព្វកិច្ចកាន់កាប់កិច្ចបញ្ជិកាគណនេយ្យ។

ផ្អែកតាមការបញ្ជាក់ខាងលើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.៣.វិធីសាស្ត្រសវនកម្ម

ប្រកាសលេខ ១៦៥ សហវ.ប្រក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ ត្រង់ប្រការ១ ចំណុចជ បានចែងថា "នាយកដ្ឋានសវនកម្មសហគ្រាស មានភារកិច្ចកសាង...នីតិវិធីសវនកម្ម រៀបចំសារាចរ និងបែបបទស្តីពីសវនកម្មលើអ្នកជាប់ពន្ធ..."។

តាមការធ្វើសវនកម្មលើសំណុំឯកសារសវនកម្មរបស់នាយកដ្ឋានសវនកម្មសហគ្រាសលើក្រុមហ៊ុនចំនួន៣៩ (ក្រុមហ៊ុនមានសកម្មភាពអាជីវកម្មអាហារ៍ណនីហារ៍ណ សេវាកម្មសណ្ឋាគារ ភោជនីយដ្ឋាន និងធនាគារ) អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានសវនកម្មសហគ្រាសពុំទាន់បានរៀបចំនីតិវិធីសវនកម្ម សារាចរ និងបែបបទស្តីពីសវនកម្មលើអ្នកជាប់ពន្ធដើម្បីឆ្លើយតបទៅនឹងហានិភ័យ (វិធីសាស្ត្រសវនកម្ម) ទៅតាមប្រភេទពន្ធ និងតាមសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធដែលត្រូវធ្វើសវនកម្មនៅឡើយ។

ការមិនបានកំណត់ និងរៀបចំនីតិវិធីសវនកម្ម សារាចរ និងបែបបទសវនកម្ម អាចនាំឲ្យលទ្ធផលនៃការធ្វើសវនកម្មសហគ្រាសនៅមានកម្រិត។

ហេតុដូចនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំឲ្យអគ្គនាយកដ្ឋានពន្ធដាររៀបចំនីតិវិធីសវនកម្ម សារាចរ និងបែបបទស្តីពីសវនកម្មលើអ្នកជាប់ពន្ធឲ្យបានឆាប់ និងទាន់ពេលវេលា។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាននិងកំពុងរៀបចំសារាចរណែនាំស្តីពីសវនកម្មមួយចំនួន ទោះបីពុំទាន់មានសារាចរណែនាំស្តីពីនីតិវិធីសវនកម្មសហគ្រាសជាផ្លូវការក្តី ក៏ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំឱ្យអគ្គនាយកដ្ឋានពន្ធដារដកស្រង់គោលការណ៍រួមនៃនីតិវិធីសវនកម្មមកអនុវត្តក្នុងការធ្វើសវនកម្មជាបណ្តើរៗ ហើយការរៀបចំសារាចរណែនាំស្តីពីនីតិវិធីសវនកម្មសហគ្រាស ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម និងក្នុងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈផងដែរ។

ផ្អែកតាមការបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.៤.ការរក្សាតួលេខសមតុល្យចុងឆ្នាំ២០១៣

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការបិទបញ្ជីចំណូល ចំណាយ និងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៣ ដោយបញ្ជាក់ថាចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬមួយពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ ដូចនេះប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ជាកំហិត។

ជាក់ស្តែង អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៅពុំទាន់បានធ្វើការផ្ទេរតួលេខចំណូលនៃគណនីលេខ៧០២៧ (អាករលើតម្លៃបន្ថែមរបបនាំ

ចូលទំនិញសម្ភារៈកសិកម្ម) និងគណនីលេខ ៧១០៧ (ពន្ធនាំចូលទំនិញជាវត្ថុធាតុដើម សម្រាប់ផលិតឱសថ) មានចំនួន ៥៤ ៥៦៧ លានរៀល ចូលថវិការដ្ឋនៅឡើយ។ ការមិនបានកត់ត្រាតួលេខចំណូលចូលថវិកាឲ្យបានគ្រប់ចំនួន និងទាន់ពេលវេលា អាចនាំឲ្យស្ថានភាពចំណូល-ចំណាយថវិកាទូទៅមិនឆ្លុះបញ្ចាំងពីសភាពជាក់ស្តែង។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអនុវត្តការកត់ត្រាចំណូលចូលថវិកាឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលាតាមឆ្នាំថវិកា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ការពុំអាចផ្ទេរតួលេខចំណូលនៃគណនីលេខ ៧០២៧ (VATសម្ភារៈកសិកម្ម) និងគណនីលេខ៧១០៧ (ពន្ធគយវត្ថុធាតុដើមផលិតឱសថ) ទាំងស្រុងទាន់ពេលវេលាតាមឆ្នាំថវិកានោះ ជារួមបណ្តាលមកពីការពុំមានឥណទានគ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់។ ដើម្បីកែលម្អករណីនេះនាពេលអនាគត តម្រូវឲ្យមានការកំណត់ឥណទានថវិកាឲ្យបានគ្រប់គ្រាន់សម្រាប់ទូទាត់តាមសំណូមពរនេះក្នុងដំណើរការកសាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងណែនាំអង្គភាពក្រោមឱវាទឲ្យខិតខំបន្ថែមទៀត ក្នុងការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.៥.ការកំណត់តម្លៃគិតពន្ធលើទំនិញមួយចំនួន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតែចេញប្រកាសស្តីពីការកែសម្រួលតារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា និងការកែសម្រួលជាបណ្តោះអាសន្ននូវតារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណា លើរថយន្តនាំចូល និងកែសម្រួលតារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញមួយចំនួន ដែលចូលមកបំពេញបែបបទគយនាំចូលចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣។ តាមការពិនិត្យជាក់ស្តែង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការកំណត់តម្លៃគិតពន្ធលើទំនិញសម្រាប់នាំចូលមួយចំនួនប្រចាំឆ្នាំ២០១៣ នៅមានតម្លៃទាបនៅឡើយ ដូចជា មាស នាឡិកាដៃ ទូរស័ព្ទដៃ និងរថយន្តជាដើម។

ការកំណត់តម្លៃក្នុងចម្លងការដែលមានកម្រិតទាប ជាហេតុនាំឱ្យការប្រមូលចំណូលនៅមានកម្រិត និងនាំឲ្យបាត់បង់ចំណូលជាយថាហេតុ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឲ្យពិនិត្យឡើងវិញលើការកំណត់តម្លៃគិតពន្ធគយសម្រាប់ទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ទន្ទឹមនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការកត់សម្គាល់មួយចំនួនដូចខាងក្រោម៖

- ពុំមានការកំណត់តម្លៃមាស១៥ដុល្លារអាមេរិកក្នុង១គីឡូក្រាមនោះទេ គឺមានតែការអនុវត្តតាមបទប្បញ្ញត្តិជាធរមានក្នុងការប្រមូលកម្រៃគយ ១៥ដុល្លារអាមេរិកក្នុងការនាំចូលមាស១គីឡូក្រាម ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

- ចំពោះតម្លៃយានយន្តម៉ាកប្រណិតមួយចំនួនដែលបានលើកឡើង ភាគច្រើនលើរថយន្តដែលកំពុងផ្សព្វផ្សាយពាណិជ្ជកម្ម និងរកទីផ្សារតាមរយៈការចាប់ដៃគូក្នុងស្រុក និងការបង្កើតបន្ទប់តាំងបង្ហាញពុំទាន់មានលក្ខណៈពាណិជ្ជកម្មពេញលេញនៅឡើយទេ។

- មុខទំនិញរថយន្តដែលមានម៉ាកប្រណិតនេះ ធ្លាប់ជាកម្មវត្ថុនៃការកំណត់តម្លៃចម្លងការសម្រាប់ពិចារណាដោយបូកបន្ថែមយ៉ាងតិច២០% លើទិន្នន័យតម្លៃរថយន្តប្រភេទទេសចរណ៍ម៉ាកមិនសូវប្រណិតផ្សេងទៀត។ គំនិតផ្តើមនេះត្រូវបានរងនូវការតវ៉ាយ៉ាងពុំរ៉ែពីសមាគមន៍អ្នកនាំចូលរថយន្តកម្ពុជា ដែលតម្រូវឱ្យមានភាពទន់ភ្លន់មួយចំនួនបន្ថែមទៀតផងដែរ ជៀសវាងការវាយតម្លៃអវិជ្ជមានពាក់ព័ន្ធនឹងការរើសអើងនានា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងពង្រឹងប្រសិទ្ធភាពការងារនេះបន្ថែមទៀតតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងតាមបទប្បញ្ញត្តិជាធរមាន តាមរយៈ (១) ការកសាងប្រព័ន្ធទិន្នន័យតម្លៃចម្លងការលម្អិតលើមុខទំនិញយានយន្ត និងមុខទំនិញរសើបផ្សេងទៀតតាមផែនការសកម្មភាពជាធរមាន ដើម្បីជាមូលដ្ឋានក្នុងការពិចារណាផ្ទៀងផ្ទាត់អនុលោមភាព (២) ការបន្តផ្សព្វផ្សាយឱ្យបានស៊ីជម្រៅដល់បុគ្គលពាក់ព័ន្ធកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការប្រកាសតម្លៃទំនិញឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន។

### ៣.១.៦.ការគ្រប់គ្រងអាជីវកម្មឆ្នោត និងល្បែងភ្នាល់

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដោយបញ្ជាក់ពីតួនាទី និងភារកិច្ចរបស់ការិយាល័យគ្រប់គ្រងល្បែងភ្នាល់ ត្រូវចុះត្រួតពិនិត្យដោយផ្ទាល់អំពីសភាពការណ៍អាជីវកម្ម និងស្ថានភាពហិរញ្ញវត្ថុ និងនៅតាមបណ្តាក្រុមហ៊ុនឆ្នោតឡូតូ ការលេងភ្នាល់កីឡា ល្បែងភ្នាល់គ្រប់ប្រភេទ និងសេវាកម្មហិរញ្ញវត្ថុនីមួយៗ ដើម្បីធ្វើសេចក្តីរាយការណ៍ប្រចាំខែ ជូនថ្នាក់ដឹកនាំក្រសួង។ ការអនុវត្តអាជ្ញាប័ណ្ណឆ្នោត ចែងថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកទទួលអាជ្ញាប័ណ្ណត្រូវធ្វើការត្រួតពិនិត្យរួមគ្នានូវចំនួនសន្លឹកឆ្នោតដែលបានលក់ ឬលិខិតគតិយុត្តនៃការធ្វើអាជីវកម្មឆ្នោតដោយផ្ទៀងផ្ទាត់ជាមួយរបាយការណ៍អាជីវកម្មប្រចាំខែរបស់ក្រុមហ៊ុន ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបញ្ជាក់ថាការបង់ចំណូលនេះ មានភាពត្រឹមត្រូវ។

ជាក់ស្តែង អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្នុងឆ្នាំ២០១៣ នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មមិន បានចុះត្រួតពិនិត្យលើក្រុមហ៊ុនមានអាជ្ញាប័ណ្ណដូចមានចែងក្នុងសេចក្តីណែនាំនោះទេ។ ម្យ៉ាងទៀត ការធ្វើអាជីវកម្មល្បែងភ្នាល់មានការផ្សងសំណាងតាមប្រព័ន្ធទូរស័ព្ទ ល្បែងកន្ទុយលេខ ល្បែងភ្នាល់តាមអ៊ីនធឺណែត (Internet) ជាដើម មិនត្រូវបានបង្ក្រាប ឬមានវិធានការសមស្របណាមួយនៅឡើយ។

ការមិនបានធ្វើការចុះត្រួតពិនិត្យ និងបង្ក្រាបការធ្វើអាជីវកម្មល្បែងភ្នាល់ផ្សេងៗនាំឲ្យការគ្រប់គ្រងអាជីវកម្មឆ្នោត និងល្បែងភ្នាល់គ្រប់ប្រភេទមិនបានពេញលេញ និងអាចនាំឲ្យបាត់បង់ចំណូលផ្សេងៗ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរជំរុញអគ្គនាយកដ្ឋាន ឧស្សាហកម្មហិរញ្ញវត្ថុឲ្យគ្រប់គ្រងអាជីវកម្មឆ្នោត និងល្បែងភ្នាល់ឲ្យបានសមស្រប។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឆ្លើយបំភ្លឺថា ការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិថា ក្នុងឆ្នាំ២០១៣ នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម មិនបានចុះត្រួតពិនិត្យលើក្រុមហ៊ុនឆ្នោតដែលមានអាជ្ញាប័ណ្ណទេ។ ជាក់ស្តែង នាយកដ្ឋាន បានចុះត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឆ្នោតទាំងនោះតាមរយៈលិខិតបញ្ជាបេសកកម្មលេខ៦៥៣ សហវ.អឧហចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ ដោយមានទាំងកំណត់ហេតុចុះត្រួតពិនិត្យទៀតផង។

រីឯការបង្ក្រាបការធ្វើអាជីវកម្មល្បែងកន្ទុយលេខ ល្បែងភ្នាល់តាមអ៊ីនធឺណែត (Internet) ល្បែងផ្សងសំណាងតាមទូរស័ព្ទ គឺជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ គណៈកម្មការចម្រុះ និងអាជ្ញាធរដែនដីស្របតាមច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។ ម្យ៉ាងទៀត ប្រភេទល្បែងខាងលើនេះ ពុំមែនជាគោលដៅប្រមូលចំណូលរបស់ក្រសួងសម្រាប់ឆ្នាំ២០១៣ និងឆ្នាំ២០១៤ ឡើយ។ ដោយឡែក ចំពោះល្បែងតាមអ៊ីនធឺណែត (Internet) ជាប្រភេទល្បែងថ្មីនៅតាមកាស៊ីណូ និងទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលរួចហើយ ហើយក្រសួងគ្រោងនឹងពិចារណាយកពន្ធនៅឆ្នាំ២០១៥ ខាងមុខនេះ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិ សង្ឃឹមថា ស្ថាប័នមានសមត្ថកិច្ចនឹងទទួលខុសត្រូវគ្រប់គ្រងល្បែងភ្នាល់គ្រប់ប្រភេទ ដើម្បីបង្កើនចំណូលដល់ថវិកាជាតិ។

**៣.១.៧.ការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច**

ការកំណត់ថ្លៃសម្បទានដី និងបង់ប្រាក់កក់ចំពោះសម្បទានដីសេដ្ឋកិច្ចទាំងអស់ (ទាំងចាស់និងទាំងថ្មី) បានបញ្ជាក់ថា ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ត្រូវបង់ថ្លៃឈ្នួលសម្បទានដីប្រចាំឆ្នាំគិតចាប់ពីឆ្នាំទី៦ទៅតម្លៃចំនួន៥ដុល្លារអាមេរិកក្នុងមួយហិកតា និងកែសម្រួលការតំឡើងថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ចពី៥%ក្នុងមួយឆ្នាំ មកនៅត្រឹម១%ក្នុងមួយឆ្នាំវិញ គិតចាប់ពីឆ្នាំទី៧តទៅ ដោយមិនធ្វើការបែងចែកទៅតាមប្រភេទដំណាំនោះទេ គឺសំដៅដល់សម្បទានដីសេដ្ឋកិច្ចដែលធ្វើអាជីវកម្មដាំដុះដំណាំកសិកម្មគ្រប់ប្រភេទ។ ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ បញ្ជាក់ថា ការពង្រឹងការគ្រប់គ្រង និងការកៀរគរចំណូលមិនមែនសារពើពន្ធដោយបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើរការផ្តល់ និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទបង់ចូលថវិកាជាតិ។

នាការិយបរិច្ឆេទឆ្នាំ២០១៣ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ចដែលហួសរយៈពេលលើកលែងចំនួន៦ឆ្នាំ នៅមានការយឺតយ៉ាវនៅឡើយ ដែលក្នុងនោះមានក្រុមហ៊ុនសរុបចំនួន៤៣ ស្មើនឹងផ្ទៃដីអាជីវកម្មចំនួន២៩៤ ៩៥១ ហិតតា នៃផ្ទៃដីដែលបានចុះកិច្ចសន្យាចំនួន ៧៨៩ ៧៧៥ ហិតតា (តួលេខនេះ មិនរាប់បញ្ចូលក្រុមហ៊ុនដែលគ្មានផែនការមេទេ)។

ការយឺតយ៉ាវក្នុងការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច នាំឲ្យការគ្រប់គ្រងដីសម្បទានមិនមានប្រសិទ្ធភាព និងបាត់ចំណូលចូលថវិការដ្ឋ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង

ស្ថាប័នពាក់ព័ន្ធ គួរជំរុញ និងពង្រឹងយន្តការនៃការប្រមូលចំណូល ដើម្បីឲ្យស្របតាមស្ថានភាពសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ការប្រមូលចំណូលពីសម្បទានដីសេដ្ឋកិច្ច ត្រូវបានកំណត់ដោយសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ៨០៣ សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ ដែលតាមស្មារតីនៃលិខិតនេះមន្ត្រីជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចុះទៅធ្វើការវាយតម្លៃ និងកំណត់ថ្លៃឈ្នួលដីសម្បទាន ដោយត្រូវកំណត់ពី០ ទៅ១០ដុល្លារអាមេរិកក្នុងមួយហិកតាក្នុងមួយឆ្នាំតាមប្រភេទដីតំបន់ និងភូមិសាស្ត្រ និងការកំណត់ពេលវេលាដែលត្រូវចាប់ផ្តើមយកថ្លៃឈ្នួលពី ២ទៅ៤ឆ្នាំ ផ្អែកលើប្រភេទដំណាំ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីអនុវត្តប៉ុន្តែកិច្ចការនេះត្រូវអូសបន្លាយដោយមានការលំបាក និងភាពស្មុគ្រស្មាញលើបញ្ហាបច្ចេកទេសក្នុងការវិភាគកំណត់យថាប្រភេទដី ដែលជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវសិក្សារៀបចំ និងការមិនមានសម្ភារនិងមធ្យោបាយក្នុងការចុះអនុវត្ត។ ដោយពិនិត្យឃើញនូវការលំបាកនេះ រាជរដ្ឋាភិបាលបានចេញនូវសេចក្តីជូនដំណឹងលេខ៦៦០សជណ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ លេខ១១៣០ សជណ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ និងលេខ១១៨៥ សជណ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១៤ ដើម្បីសម្រួលកិច្ចការប្រមូលចំណូលក្នុងផ្នែកនេះ ដោយកំណត់ឱ្យប្រាក់កក់១០ដុល្លារអាមេរិកក្នុងមួយហិកតា បង់ថ្លៃឈ្នួលដីសម្បទាន គិតចាប់ពីឆ្នាំទី០៦ក្រោយចុះកិច្ចសន្យាក្នុងតម្លៃ៥ដុល្លារអាមេរិកក្នុងមួយហិកតា ក្នុងមួយឆ្នាំនៃផ្ទៃដីដែលបានអនុញ្ញាតឱ្យឈូសឆាយ និងកើនឡើង១ភាគរយរៀងរាល់ឆ្នាំចាប់ពីឆ្នាំទី៦តទៅ ដោយមិនធ្វើការបែងចែកទៅតាមប្រភេទដំណាំនោះទេ។

អនុវត្តគោលការណ៍ថ្មីនាចុងឆ្នាំ២០១២នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកែសម្រួលគណៈកម្មការអន្តរក្រសួងដោយជំហានដំបូងបានធ្វើការរៀបចំនីតិវិធី និងបានចុះកំណត់ថ្លៃឈ្នួលជាបន្តបន្ទាប់។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យនូវវឌ្ឍនភាព - នឹងសង្ឃឹមថាសម្បទានដីសេដ្ឋកិច្ច នឹងនាំមកនូវប្រសិទ្ធភាពសេដ្ឋកិច្ចសង្គមជូនជាតិ ។

### ៣.១.៨.ការប្រមូលចំណូលពីការអនុញ្ញាតផ្សព្វផ្សាយពាណិជ្ជកម្ម

ប្រកាសរួមលេខ១០០៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាន ត្រង់ប្រការ១ បានចែងថា "អនុញ្ញាតឲ្យក្រសួងព័ត៌មានអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។ តាមតារាងឧបសម្ព័ន្ធភ្ជាប់នៃប្រកាសរួមខាងលើនេះបានតម្រូវឲ្យក្រសួងព័ត៌មានប្រមូលចំណូលពីការអនុញ្ញាតឲ្យផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយផ្សេងៗ ដូចជា " តាមប៉ាណូតាមមធ្យោបាយដឹកជញ្ជូន តាមអាហ្វីស តាមភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម..." ។

តាមការធ្វើសវនកម្មលើរបាយការណ៍បូកសរុបសកម្មភាពការងារឆ្នាំ២០១៣ និងទិសដៅឆ្នាំ២០១៤របស់អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ និងរបាយការណ៍ចំណូលដែលប្រមូលបានពីកម្រៃសេវាសាធារណៈប្រចាំឆ្នាំ២០១៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងព័ត៌មានមិនទាន់បានប្រមូលចំណូលពីការអនុញ្ញាតការផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូ ពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ តាមអាហ្វីស និងតាមភ្នាក់ងារផ្សាយពាណិជ្ជកម្ម ឱ្យបានសមស្របនៅឡើយ ។

ដោយហេតុនេះ ក្រសួងព័ត៌មាន គួរអនុវត្តតាមខ្លឹមសារនៃប្រកាសខាងលើនេះឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ឆ្លើយតបនឹងចំណុចខាងលើ ក្រសួងព័ត៌មានសូមធ្វើការបញ្ជាក់ និងទទួលស្គាល់ថា ពិតជាមិនទាន់ប្រមូលចំណូលពីការផ្សព្វផ្សាយពាណិជ្ជកម្មចូលថវិការដ្ឋពិតប្រាកដមែន ដោយសារច្បាប់នេះទើបតែចេញឲ្យអនុវត្ត ហើយក្រសួងពុំទាន់បានរៀបចំនីតិវិធីក្នុងការគ្រប់គ្រងប្រមូលចំណូលពីការផ្សព្វផ្សាយពាណិជ្ជកម្ម និងចំណូលនេះ កន្លងមកមានការប្រមូលពីស្ថាប័នផ្សេងៗផង ដូចជាសាលាក្រុង ផ្នែកពន្ធដារជាដើម ដែលជាហេតុធ្វើឱ្យអតិថិជនមានការបង់ចំណូលនេះច្រើនផ្នែក និងធ្វើឲ្យក្រសួងមានការពិបាកក្នុងការបង្ខំឱ្យអតិថិជនមកធ្វើការសុំអាជ្ញាប័ណ្ណ និងបង់ចំណូល។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យនូវវឌ្ឍនភាព ។

**៣.១.៩.ការអនុវត្តចំណាយចរន្តសម្រាប់គម្រោងវិនិយោគ**

អនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រង់មាត្រា១ ចែងថា ឥណទានចំណាយថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវបែងចែកតាមក្រសួងនីមួយៗ តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកនៃចំណាត់ថ្នាក់ សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលក្នុងនោះត្រូវបានបែងចែកទឹកប្រាក់ចំណាយមិនទាន់បែងចែកចំនួន ៥ ៦២៨ ៩២៦លានរៀល ដោយរួមមានជំពូក៦៥ ចំណាយចរន្តក្នុងការអនុវត្តគម្រោងមានទឹកប្រាក់ចំនួន ១៣០ ០០០លានរៀល។

តាមការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានថវិកា (នាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល) អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ការចំណាយចរន្តក្នុងការអនុវត្តគម្រោងសម្រាប់ការិយបរិច្ឆេទ២០១៣ របស់នាយកដ្ឋានសហប្រត្តិបត្តិការ និងគ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុវត្តលើសពីឥណទានចំណាយដែលបានកំណត់ នាំឲ្យការអនុវត្តចំណាយប្រចាំឆ្នាំមិនបានត្រឹមត្រូវសមស្របតាមច្បាប់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំអគ្គនាយកដ្ឋានថវិកាឲ្យអនុវត្តថវិកាឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ចំណាយចរន្តសម្រាប់គម្រោងវិនិយោគក្នុងការិយបរិច្ឆេទឆ្នាំ២០១៣ បានអនុវត្តលើសច្បាប់ហិរញ្ញវត្ថុចំនួន **៨៧ ៧២៩ ១៣១** រៀល គឺបណ្តាលមកពីការរៀបចំគ្រោងថវិកាមិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងស្ថានភាពនៃការអនុវត្តជាក់ស្តែង

របស់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយពេលខ្លះចំណាយប្រភេទនេះមានភាពចាំបាច់បន្ទាន់ និងមិនអាចដឹងមុន ហើយប្រសិនបើមិនធ្វើការទូទាត់ទេ គឺអាចធ្វើឲ្យរាំងស្ទះដល់ការអនុវត្តគម្រោងទាំងនោះ។

**៣.១.១០.ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈមិនស្របតាមផែនការ**

អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ ត្រង់មាត្រា៧ បានចែងថា "រាល់កិច្ចលទ្ធកម្មត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធី ដើម្បីធានាឱ្យកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅប្រកបដោយតម្លាភាព ភាពយុត្តិធម៌ សមធម៌ និងការប្រកួតប្រជែងពេញលេញ"។ សារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រង់ចំណុច II បានបញ្ជាក់ថា "រាល់គម្រោងចំណាយដែលត្រូវអនុវត្តតាមវិធីសាស្ត្រនីតិវិធីលទ្ធកម្ម ត្រូវកត់ត្រាទាំងអស់តាមលំដាប់លំដោយបញ្ចូលក្នុងផែនការលទ្ធកម្ម។ ករណីមិនមានកត់ត្រាក្នុងផែនការលទ្ធកម្ម មិនត្រូវបានអនុញ្ញាតឲ្យធ្វើកិច្ចលទ្ធកម្មឡើយ ហើយសាមីស្ថាប័នអនុវត្តកិច្ចលទ្ធកម្ម ត្រូវទទួលខុសត្រូវលើរាល់បាតុភាពអសកម្ម ដែលនឹងកើតឡើងដោយយថាហេតុ"។

តាមការធ្វើសវនកម្មលើតារាងផែនការលទ្ធកម្ម និងរបាយការណ៍ស្តីពីការអនុវត្តលទ្ធកម្មសាធារណៈប្រចាំឆ្នាំ២០១៣របស់ក្រសួងផែនការ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងផែនការធ្វើការអនុវត្តកិច្ចលទ្ធកម្មលើការទិញកុំព្យូទ័រ (Desktop) កុំព្យូទ័រ (Laptop) ព្រីនធ័រ ហ្វូតូកូពី តុការិយាល័យ កៅអីការិយាល័យ និងទូរឯកសារ មានទឹកប្រាក់សរុបចំនួន ៦.៤៧០.៥៥០.០០០រៀល មិនស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំនៅឡើយ ដោយបង្វែរពីការដេញថ្លៃជាលក្ខណៈអន្តរជាតិមកធ្វើការដេញថ្លៃក្នុងស្រុក។

អាស្រ័យហេតុនេះ ក្រសួងផែនការ គួរអនុវត្តឱ្យត្រឹមត្រូវតាមខ្លឹមសារនៃអនុក្រឹត្យខាងលើនេះ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងផែនការបានបញ្ជាក់ថានឹងលើកទិសដៅអនុវត្តនៅឆ្នាំបន្ទាប់។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

**៣.១.១១.ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ**

ដើម្បីពង្រឹងកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅប្រកបដោយតម្លាភាព សមភាព ការប្រកួតប្រជែង ភាពតែមួយនៃនីតិវិធីលទ្ធកម្ម ការធានាឲ្យសម្រេចបាននូវភាពសន្សំសំចៃ គណនេយ្យភាព និងប្រសិទ្ធភាពក្នុងដំណើរការលទ្ធកម្មទាក់ទងនឹងទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា។ ដើម្បីអនុវត្តកិច្ចការទាំងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញនូវអនុក្រឹត្យ លេខ១០៥អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីលទ្ធកម្មសាធារណៈ និងសារាចរណែនាំលេខ០០៦សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់។

ប្រការនេះបញ្ជាក់ថា រាល់កិច្ចលទ្ធកម្មត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធី ដើម្បីធានាឲ្យកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅប្រកបដោយតម្លាភាព ភាពយុត្តិធម៌ សមធម៌ និងប្រកួតប្រជែងពេញលេញ″ និងមិនអនុញ្ញាតឲ្យមានជាដាច់ខាតចំពោះការបំបែងគម្រោងទៅជាគម្រោងតូចៗ ដើម្បីបញ្ចៀសការដេញថ្លៃជាសាធារណៈ ឬតម្រូវតាមសិទ្ធិសម្រេចរបស់ខ្លួន″ និងត្រង់ចំណុចទី III ត្រង់ទី៤ បានចែងថា "ត្រូវប្រមូលផ្តុំតម្រូវការដែលស្ថិតក្នុងប្រភេទដូចគ្នា ហើយមានលក្ខណៈបច្ចេកទេសដូចគ្នា ឬស្រដៀងគ្នា ចាំបាច់ត្រូវបញ្ចូលក្នុងក្រុមតែមួយដែលហៅថាឡូត៍លទ្ធកម្ម ដើម្បីធ្វើកិច្ចលទ្ធកម្មតែមួយលើក និងឡូត៍លទ្ធកម្មមួយចំនួនដែលមានភាពប្រហាក់ប្រហែល ឬស្រដៀងគ្នាត្រូវបញ្ចូលគ្នាជាក្រុមធំមួយ ហៅថា កញ្ចប់លទ្ធកម្មសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក"។

តាមការធ្វើសវនកម្មលើផែនការលទ្ធកម្ម និងរបាយការណ៍អនុវត្តលទ្ធកម្មឆ្នាំ២០១៣ របស់ក្រសួងព័ត៌មាន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងផែនការលទ្ធកម្មមានចំនួន១៨គម្រោង ដែលមានទឹកប្រាក់សរុបចំនួន៤១ ២៦១ពាន់លានរៀល ក្នុងនោះមាន០៥គម្រោងត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃអន្តរជាតិ និង១៣គម្រោងត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃក្នុងស្រុក។ ប៉ុន្តែនៅក្នុងរបាយការណ៍អនុវត្តកិច្ចលទ្ធកម្ម ក្រសួងបានអនុវត្តកិច្ចលទ្ធកម្មចំនួន១៦០គម្រោង ដែលមានទឹកប្រាក់សរុបចំនួន៤០ ៧០៧ពាន់លានរៀល ទៅតាមវិធីសាស្ត្រដូចខាងក្រោម៖

- ដេញថ្លៃក្នុងស្រុក ១៨គម្រោងមានទឹកប្រាក់............... ២៧ ២៨២ ៧០០ ០០០រៀល
- ពិគ្រោះថ្លៃ១៤១គម្រោងមានទឹកប្រាក់..........................១៣ ៤១៥ ០០០ ០០០រៀល
- ស្ទង់តម្លៃ០១គម្រោងមានទឹកប្រាក់........................................៩ ៤០០ ០០០រៀល

ប្រការដែលក្រសួងព័ត៌មានធ្វើការបំបែកគម្រោងលទ្ធកម្ម ដើម្បីគេចចេញពីការដេញថ្លៃសាធារណៈនោះ ដោយសារតែក្រសួងមានការខ្វះខាតនូវសម្ភារប្រើប្រាស់មួយចំនួន ប្រសិនបើរង់ចាំការអនុវត្តការដេញថ្លៃជាធារណៈនោះ ធ្វើឲ្យមានការខ្វះខាតសម្ភារសម្រាប់ដំណើរការការងាររបស់ក្រសួង។

នៅក្នុងរបាយការណ៍អនុវត្តលទ្ធកម្ម និងសំណុំឯកសារទូទាត់ ការចំណាយបោះពុម្ពក្នុងឆ្នាំ២០១៣ របស់ក្រសួងផែនការ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងពុំបានប្រមូលផ្តុំកិច្ចលទ្ធកម្មចំនួន៧ អាណត្តិ មានទឹកប្រាក់ចំនួន ៥៧៩ ១៤០ ០០០ រៀល ដែលស្ថិតនៅក្នុងប្រភេទដូចគ្នា ឬស្រដៀងគ្នា ដើម្បីធ្វើលទ្ធកម្មតែមួយលើក។

ការអនុវត្តបែបនេះ អាចនាំឲ្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈពុំទាន់បានល្អ។ ដូច្នេះក្រសួងត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យ និងសារាចរខាងលើ ឲ្យមានប្រសិទ្ធភាព ។

ឆ្លើយតបទៅនឹងចំណុចខាងលើនេះ៖

- ក្រសួងព័ត៌មានបានបញ្ជាក់ និងទទួលស្គាល់ថា ពិតជាមានការអនុវត្តកិច្ចលទ្ធកម្មមានការពិគ្រោះថ្លៃច្រើន ដោយសារតែសម្ភារមួយចំនួនធំក្រសួងត្រូវការជាចាំបាច់ និងបន្ទាន់ពុំអាចរង់ចាំការដេញថ្លៃប្រកួតប្រជែងជាសាធារណៈបាន ព្រោះការដេញថ្លៃប្រជែងជាសាធារណៈប្រើ

រយៈពេលយូរ។ ទោះជាយ៉ាងណាក្រសួងបាននិងកំពុងខិតខំអនុវត្តទៅតាមវិធីសាស្ត្រលទ្ធកម្មឲ្យបានត្រឹមត្រូវប្រសើរឡើង។ ក្រសួងព័ត៌មានទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងខិតខំអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ១០៥អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ និងសារាចរណែនាំលេខ០០៦សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

- ក្រសួងផែនការបានបំភ្លឺថា ការងារគោលនយោបាយរបស់នាយកដ្ឋាននីមួយៗនៅអគ្គនាយកដ្ឋានផែនការ និងវិទ្យាស្ថានជាតិស្ថិតិ មានគោលនយោបាយខុសៗគ្នា រីឯពេលវេលាដែលផ្សព្វផ្សាយអនុវត្តក៏ខុសគ្នាដែរ ទើបនាយដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ (គ.ប.វ.ប) នៃក្រសួងផែនការមិនអាចអនុវត្តកិច្ចលទ្ធកម្មជាឡូត៍លទ្ធកម្មបានឡើយ។ ចំពោះការអនុវត្តកិច្ចលទ្ធកម្មនៅឆ្នាំ២០១៣ ក្រសួងផែនការ ក៏បានអនុវត្តតាមការសម្រេចក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៣ផងដែរ (ទិដ្ឋាការឯកភាពលេខ ១៤៦/សហវ.លសា ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។

ផ្អែកលើការបំភ្លឺ អាជ្ញាធរសវនកម្មជាតិនឹងពិនិត្យនូវវឌ្ឍនភាពការងារនេះជាបន្ត។

## ៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១.ការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការាជធានី ខេត្ត និងក្រុង ស្រុក ត្រង់ឧបសម្ព័ន្ធ២ ជំពូក២១ គណនី២១៣ បានអនុញ្ញាតឲ្យខេត្ត ក៏ដូចជាបណ្តាមន្ទីរជុំវិញ អនុវត្តមាតិកាចំណាយថវិការបស់ខ្លួនឲ្យបានសមស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនោះ ៖ អនុគណនី ២១៣១ ស្តីពីសំណង់អគារ អនុគណនី២១៣២ ស្តីពីការរៀបចំកែលម្អអគារ និងអនុគណនី ២១៣៨ ស្តីពីសំណង់ផ្សេងៗទៀត។ រីឯ ជំពូក៦១ កត់ត្រា (៦១៥២)ការចំណាយលើការ ថែទាំ ជួសជុលអគារ និងប្រាសាទ។

តាមការធ្វើតេស្តលើសំណុំឯកសារលទ្ធកម្មនៅខេត្តចំនួន០៤ គឺខេត្តកំពង់ចាម កំពង់ធំ ក្រចេះ និងខេត្តកណ្តាល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណាបក្សប្រទានសិទ្ធ និងអភិបាលហិរញ្ញវត្ថុខេត្តបានអនុញ្ញាតឲ្យសាលាខេត្ត និងមន្ទីរជុំវិញខេត្តមួយចំនួនយកថវិកាជំពូក ៦១ គណនី ៦១៥ អនុគណនី ៦១៥២ មកចំណាយលើការងារសាងសង់អគារ របង ស្ពាន ផ្លូវទៅវិញ។

ដោយសារការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា បានធ្វើឲ្យប៉ះពាល់ដល់គោលនយោបាយហិរញ្ញវត្ថុ និងតួលេខនៃគណនីចំណាយក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្លុះបញ្ចាំងមិនពិតប្រាកដ។

អាស្រ័យហេតុនេះ សាលាខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពដែលអនុវត្តគម្រោងចំណាយគួរអនុវត្តតាមប្រកាសស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តបានឯកភាព និងបានឲ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រជុំពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីណែនាំអនុវត្តឱ្យបានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យពីវឌ្ឍនភាព ។

### ៣.២.២.ការមិនបានចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីតាមដានការងារសំណង់

ប្រកាសលេខ ៣៨១ ប្រក/សហវ.២០១០ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឲ្យប្រើសៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី២ ចំណុច៣.១៤.៨ បានបញ្ជាក់ថា៖ ជាទូទៅការត្រួតពិនិត្យកិច្ចសន្យាសំណង់មានការស្មុគស្មាញ ដោយសារកត្តាទាំងឡាយដែលមិនអាចដឹងបានមុនពេលចាប់ផ្តើមការងារ។ ដូច្នេះ តម្រូវឲ្យមានការចាត់តាំងអ្នកគ្រប់គ្រងគម្រោងដើម្បីធ្វើការគ្រប់គ្រងទីតាំងគម្រោង និងត្រួតពិនិត្យសកម្មភាពប្រចាំថ្ងៃរបស់ "អ្នកទទួលការ"។ អ្នកគ្រប់គ្រងគម្រោងអាចជាបុគ្គលនៅក្នុងអង្គភាពលទ្ធកម្ម ឬជាទីប្រឹក្សាជំនាញ ឬជាបុគ្គលដែលមានជំនាញមកពីស្ថាប័នអនុវត្តលទ្ធកម្ម។ អ្នកគ្រប់គ្រងគម្រោងត្រូវធ្វើរបាយការណ៍ជាប្រចាំអំពីវឌ្ឍនភាព និងបញ្ហាដែលកើតមានឡើងក្នុងពេលអនុវត្តការងារ។

តាមការធ្វើតេស្តសវនកម្មលើសំណុំឯកសារលទ្ធកម្មនៅខេត្តចំនួន០៤ គឺខេត្តកំពង់ចាម កំពង់ធំ ក្រចេះ និងខេត្តព្រៃវែង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ខេត្តទាំងនោះពុំបានចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីតាមដានការងារសាងសង់របស់អ្នកទទួលការ និងធ្វើរបាយការណ៍វឌ្ឍនភាពចំពោះការសាងសង់សំណង់អគារ ផ្លូវ...ឡើយ។

ដោយសារការពុំបានចាត់តាំងឱ្យមានអ្នកគ្រប់គ្រងគម្រោង អាចជាហេតុនាំឱ្យការវាយតម្លៃរបស់គណៈកម្មការប្រគល់ទទួលសំណង់ពុំមានមូលដ្ឋានច្បាស់លាស់ ហើយសំណង់អាចខុសប្លង់បច្ចេកទេស និងមានគុណភាពមិនសូវល្អ។

អាស្រ័យហេតុនេះ សាលាខេត្ត គួរណែនាំអង្គភាពលទ្ធកម្ម និងអង្គភាពអនុវត្តលទ្ធកម្ម ឲ្យមានការចាត់តាំងអ្នកគ្រប់គ្រងគម្រោង ដើម្បីតាមដានរាល់ការងាររបស់អ្នកទទួលការ និងរាល់បញ្ហាដែលកើតមានក្នុងអំឡុងពេលអនុវត្តការងារ ព្រមទាំងរាយការណ៍ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពជូនថ្នាក់ដឹកនាំជាប្រចាំ។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តបានឯកភាព ហើយសន្យាថានឹងរៀបចំការងារនេះនាពេលខាងមុខ។

### ៣.២.៣.ការចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារ បរិក្ខារ និងគ្រឿងចក្រសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញប្រកាសលេខ៧៦ប្រក/ដ.ន.ស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងតួនាទីភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ ត្រង់ចំណុច ២ បានកំណត់ឲ្យមន្ទីរត្រូវចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារ បរិក្ខារ និងគ្រឿងចក្រសំណង់ ដែលប្រែប្រួលតាមខេត្ត ក្រុង។

តាមរយៈការធ្វើតេស្តសវនកម្មនៅខេត្តចំនួន០៥ គឺខេត្តកំពង់ចាម កំពង់ធំ ក្រចេះ ប៉ៃលិន និងខេត្តសៀមរាម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តទាំងនេះមិនបានចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារ បរិក្ខារ និងគ្រឿងចក្រសំណង់ទេ។

ដោយសារការខកខានមិនបានចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារ បរិក្ខារ និងគ្រឿងចក្រសំណង់នាំឲ្យការត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងចំណាយរបស់អភិបាលហិរញ្ញវត្ថុ និងអាណាប័កប្រទានសិទ្ធិពុំមានមូលដ្ឋានច្បាស់លាស់ឡើយ ហើយតម្លៃនៃគម្រោងអាចខ្ពស់ជាងតម្លៃទីផ្សារជាក់ស្តែង។

អាស្រ័យហេតុនេះ សាលាខេត្ត គួរណែនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីឲ្យចងក្រងនូវបញ្ជីតម្លៃពលកម្ម សម្ភារ បរិក្ខារ និងគ្រឿងចក្រសំណង់ទុកសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃគម្រោងចំណាយរបស់ខ្លួន។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តបានឯកភាព និងបានសន្យាថា នឹងណែនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីឲ្យរៀបចំចងក្រងបញ្ជីនេះ។

## ៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តន៍អនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៣ និងនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួន ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឲ្យកត់សម្គាល់ និងកោតសសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

**៤.១. ការបំពេញកាតព្វកិច្ចសារពើពន្ធ:** ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់សារពើពន្ធបានកំណត់ឲ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់។ តាមការធ្វើសវនកម្មលើបញ្ជីឈ្មោះក្រុមហ៊ុនសហគ្រាសដែលបានចុះបញ្ជី និងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធចំពោះ លោក លោកស្រី នាយកក្រុមហ៊ុន សហគ្រាសនីមួយៗឲ្យមកដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធប្រចាំខែ ប្រចាំឆ្នាំ នៅអង្គភាពពន្ធ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៣ មានក្រុមហ៊ុនចំនួន៦០៩ ក្នុងចំណោម ២ ៣៩៥ ក្រុមហ៊ុន មិនបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ២០១៣ទេ ទោះបីរដ្ឋបាលសារពើពន្ធបានធ្វើលិខិតរំលឹកស្តីពីការប្រកាសពន្ធ មួយលើក ពីរលើក ឬបីលើក បន្ថែមទៀតក៏ដោយ ក៏ក្រុមហ៊ុនសហគ្រាសទាំងនោះមិនយកចិត្តទុកដាក់មកដាក់លិខិតប្រកាសពន្ធ ដើម្បីបំពេញកាតព្វកិច្ចសារពើពន្ធឲ្យបានសមស្របតាមច្បាប់ស្តីពីសារពើពន្ធដែរ។

**៤.២. របាយការណ៍សវនកម្មរបស់សវនកររឯករាជ្យ៖** សហគ្រាសវិនិយោគទាំងឡាយ ដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនកររឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១)ផលរបរប្រចាំឆ្នាំសហគ្រាសមានចំនួន

ចាប់ពីបីពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ។ ក្នុងឆ្នាំ២០១៣ នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ បានចុះធ្វើសវនកម្មលើសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យ ត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យចំនួន១៤០ ឃើញមានសហគ្រាសចំនួន១៦ ពុំមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យឡើយ។

**៤.៣. ការប្រមូលពន្ធអចលនទ្រព្យ៖** គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យបានតម្រូវឲ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ ការអនុវត្តប្រមូលពន្ធអចលនទ្រព្យនៅមានកម្រិតនៅឡើយ ដោយសារអ្នកជាប់ពន្ធមួយចំនួនមិនបានផ្តល់ព័ត៌មានអំពីអចលនទ្រព្យ មិនមកចុះបញ្ជីពន្ធអចលនទ្រព្យ មិនមកប្រកាសបង់ពន្ធលើអចលនទ្រព្យ និងអ្នកជាប់ពន្ធមួយចំនួនទៀតបានចុះបញ្ជីពន្ធអចលនទ្រព្យរួចហើយ ប៉ុន្តែមិនព្រមមកបង់ពន្ធ។

**៤.៤. ការគ្រប់គ្រងអ្នកជាប់ពន្ធតាមរបបម៉ៅការ៖** ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ បានកំណត់ថា អ្នកជាប់ពន្ធតាមរបបម៉ៅការមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំយ៉ាងយឺតបំផុតនៅថ្ងៃទី៣១ ខែតុលា។ ចំនួនទឹកប្រាក់ម៉ៅការត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានពិនិត្យ និងពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬអ្នកតំណាង និងប្រាក់ចំណេញទៅតាមប្រភេទ និងតាមមុខរបរអាជីវកម្មដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការកម្រិតពន្ធលើប្រាក់ចំណេញម៉ៅការត្រូវកំណត់ជាស្ថិរវន្តសម្រាប់រយៈពេលមួយកំណត់៣ខែ ៦ខែ ឬមួយឆ្នាំ អ្នកជាប់ពន្ធលើប្រាក់ចំណេញរបបម៉ៅការត្រូវបង់ពន្ធនេះជារៀងរាល់ខែតាមពេលវេលា ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ភាគច្រើនមន្ត្រីពន្ធដារនៃសាខាពន្ធដារខណ្ឌ និងខេត្តនានាបានចុះប្រមូលប្រាក់ពន្ធដល់អាជីវកម្មដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនផ្ទាល់ ពោលគឺម្ចាស់អាជីវកម្មដ្ឋានពុំបានទៅបង់ពន្ធនៅរដ្ឋបាលសារពើពន្ធនោះទេ។

**៤.៥. ការបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស៖** ច្បាប់ស្តីពីសារពើពន្ធសហគ្រាសកំណត់ថា ក្រោយពីចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរួចហើយ សហគ្រាសត្រូវរួសរាន់ទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង១៥ថ្ងៃ។ ក្នុងករណីមិនបានទៅចុះបញ្ជីទេនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីចាប់តាំងពីពេលដែលសហគ្រាសត្រូវទៅចុះបញ្ជី ហើយការចុះបញ្ជីបែបនេះសហគ្រាសត្រូវមានការទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ចាប់តាំងពីកាលបរិច្ឆេទដែលបានកំណត់។ ប៉ុន្តែ តាមការធ្វើតេស្តសហគ្រាសចំនួន២៨៨ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ២០១៣ អាជ្ញាធរសវនកម្មជាតិរកឃើញថា មានសហគ្រាសចំនួន១២៩ បានមកបំពេញកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ រីឯចំនួនសហគ្រាសនៅសល់ពីនេះពុំមានប្រភពបញ្ជាក់ច្បាស់លាស់ឡើយ។

**៤.៦. ការប្រកាសពន្ធរបស់សហគ្រាស៖** ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជា

អ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មសង្កេតឃើញថា មានសហគ្រាសមួយចំនួន បានដាក់លិខិតប្រកាសពន្ធដោយប្រកាសតម្លៃលក់ទាបជាងតម្លៃទីផ្សារ និងក្រុមហ៊ុនមួយចំនួនទៀតបានប្រកាសពន្ធមិនត្រឹមត្រូវ និងសមស្របលើពន្ធកាត់ទុក។

**៤.៧. ការប្រមូលពន្ធតាមរបបមៅការៈ** ការប្រមូលពន្ធតាមរបបនេះអាចប្រព្រឹត្តទៅបានពេញលេញលុះត្រាតែអាជីវកម្មដ្ឋានទាំងឡាយត្រូវបានចុះបញ្ជីអនុម័តពន្ធត្រឹមត្រូវ។ រដ្ឋបាលសារពើពន្ធ មានតួនាទីជំរឿនអ្នកជាប់ពន្ធ កំណត់ពន្ធ និងដាក់បញ្ចូលអាជីវកម្មក្នុងបញ្ជីអនុម័តពន្ធ។ ប៉ុន្តែតាមការធ្វើសវនកម្មអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាជីវកម្មដ្ឋានមួយចំនួនមិនទាន់ត្រូវបានបញ្ចូលទៅក្នុងបញ្ជីអនុម័តពន្ធនោះទេ។

**៤.៨. ការតាមដានលើការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធៈ** នាយកដ្ឋានរបបគយនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មានតួនាទីភារកិច្ចធ្វើការតាមដានសម្ភារ បរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះពន្ធនានាតាមទិសដៅដែលបានកំណត់ និងត្រួតពិនិត្យលើការប្រើប្រាស់ដោយរួមទាំងការចុះទៅបំពេញភារកិច្ចតាមដាន និងឃ្លាំមើលជាអចិន្ត្រៃយ៍ ឬលក្ខណៈម្តងម្កាលតាមបណ្តាអាជីវកម្មដ្ឋាន ឬពាណិជ្ជកម្មនានាស្របតាមនីតិវិធីច្បាប់ជាធរមាន។ ប៉ុន្តែតាមការធ្វើសវនកម្មអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ពុំមានឯកសារ ឬរបាយការណ៍ ឬកំណត់ហេតុ ដែលអាចបញ្ជាក់ថានាយកដ្ឋាននេះបានធ្វើការត្រួតពិនិត្យតាមដានលើការប្រើប្រាស់សម្ភារ បរិក្ខារ និងវត្ថុធាតុដើមទាំងឡាយដែលបាននាំចូលដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋនោះឡើយ ដោយពង្រឹងប្រសិទ្ធភាពការអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញវិញ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានទទួលស្គាល់នូវការយឺតយ៉ាវមួយចំនួនក្នុងការងារនេះ ទោះបីមានការខិតខំនានាដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធឱ្យប្រើប្រាស់បានចំទិសដៅ និងតាមលក្ខខណ្ឌរបបអនុគ្រោះនីមួយៗនោះក្តី។ ទន្ទឹមនេះឃើញមាននូវវឌ្ឍនភាពមួយចំនួនដូចខាងក្រោមៈ

ក. បានបន្តផ្សព្វផ្សាយនូវបទប្បញ្ញត្តិជាធរមាននានាដល់វិស័យឯកជនពាក់ព័ន្ធ តាមរយៈការចែកផ្សាយនូវសៀវភៅមគ្គុទេសក៍សវនកម្មពាក់ពន្ធ័នឹង (១)ការគ្រប់គ្រងទំនិញដែលត្រូវលើកលែងពន្ធនិងអាករ (២)ការគ្រប់គ្រងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀតស្តីពីការនាំចេញនិងនាំចូល (៣)យន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ (៤)ការនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក និង (៥)ការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធនិងអាករ។

ខ. បានដាក់ឱ្យដំណើរការអង្គភាពសវនកម្មគយចំនួន៦ ដែលបានចាប់ផ្តើមការផ្ទៀងផ្ទាត់អនុលោមភាពទំនិញនាំចូលក្រោមរបបអនុគ្រោះទាំងនេះចាប់ពីឆ្នាំ២០១៣មក ដោយផ្តោតសំខាន់លើវិស័យកាត់ដេរ និងកំពុងដំណើរការពង្រីកភាពគ្របដណ្តប់ទៅវិស័យផ្សេងទៀត។ សមាសភាពក្នុងអង្គភាពសវនកម្មគយនេះមានការចូលរួមពីមន្ត្រីជំនាញនៃនាយកដ្ឋានរបបគយមួយចំនួនផងដែរ។ ចំពោះបណ្តាអង្គទូតនិងអង្គការប្រហាក់ប្រហែលនានានោះ ការផ្ទៀងផ្ទាត់អនុលោមភាពត្រូវបានធ្វើជាបន្តបន្ទាប់ ជាពិសេសលើមុខទំនិញយានយន្តនៅពេលមានការនាំចូលថ្មីឬផ្ទេរទៅតតិយជន។

ទន្ទឹមនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នឹងខិតខំពង្រឹងសមត្ថភាពបន្ថែមទៀតក្នុងការអនុវត្តការងារនេះតាម (១)អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ (២)បទប្បញ្ញត្តិជាធរមាន និង (៣) យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ទោះបីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយជាការងារថ្មី និងមានវេទយិតភាពខ្ពស់ជាពិសេសលើវិនិយោគិន និងឯកសិទ្ធិបុគ្គលមួយចំនួនដែលតម្រូវឱ្យមានភាពទន់ភ្លន់ ការផ្សព្វផ្សាយទូលំទូលាយ ការសហការយល់គ្នាទៅវិញទៅមក និងការចូលរួមពីផ្នែកពាក់ព័ន្ធ"។

**៤.៩. ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ៖** ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ បានបញ្ជាក់ថា ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុមានគោលបំណង ដើម្បីជំរុញឲ្យមានការអភិវឌ្ឍអចលនវត្ថុមួយដែលមានភាពទុកចិត្ត និងទទួលយកបានតាមរយៈការត្រួតពិនិត្យគម្រោងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ គ្រប់គ្រងគម្រោងហិរញ្ញវត្ថុ គណនីអភិវឌ្ឍអចលនវត្ថុ និងការធ្វើសវនកម្មលើការអនុវត្តកិច្ចសន្យាទិញ លក់ និងបង្កើនទំនុកចិត្តរបស់អតិថិជនក្នុងការវិនិយោគលើអចលនវត្ថុ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនមួយចំនួនបានធ្វើអាជីវកម្មដោយមានការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មត្រឹមត្រូវពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះដែរ ក៏មានក្រុមហ៊ុនមួយចំនួនទៀតដែលបាននិងកំពុងធ្វើអាជីវកម្ម ពុំមានអាជ្ញាប័ណ្ណអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ។

**៤.១០. ការកត់ត្រាចំណូលថវិការដ្ឋ៖** បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈកំណត់ថា ការកត់ត្រាចំណូលថវិកាត្រូវផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កក្រសួង ស្ថាប័ន រាជធានី ខេត្តដែលបានរៀបចំបញ្ជូនទៅឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការផ្ទៀងផ្ទាត់។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចំណូលមួយចំនួនមិនត្រូវបានកត់ត្រាដោយផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កនៅឡើយដោយសារក្រសួង ស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកប័ត្រចំណូលមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ។ ករណីទាំងនេះពាក់ព័ន្ធនឹងប្រភេទចំណូលមួយចំនួនដែលបានកើតមាននៅពេលកៀកចុងឆ្នាំ ហើយជាប្រភេទចំណូលដែលគ្រាន់តែធ្វើនិយ័តកម្មតួលេខដូចជា៖ ចំណូលពីលំអៀងលើសនៃអត្រាប្តូរប្រាក់ ចំណូលពីកម្រៃរតនាគារ ចំណូលពីវិសមភាពបេឡា និងខ្ទង់ចំណូលមួយចំនួនទៀតនៅកៀកចុងឆ្នាំ និងចំណូលពីឈ្នួលទីតាំងដែលធនាគារជាតិនៃកម្ពុជាបានបញ្ជូនប្រកាសឥណទានមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិហើយ ប៉ុន្តែក្រសួង ស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកប័ត្រចំណូលមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ ហើយដែលរតនាគារជាតិត្រូវបង្ខំចិត្តធ្វើការកត់ត្រាឲ្យបានទាន់ពេលវេលានៅពេលបិទបញ្ជីចុងឆ្នាំ។ បញ្ហានេះប្រសិនបើអគ្គនាយកដ្ឋានរតនាគារជាតិមិនបានកត់ត្រាជាចំណូលទេនោះ នឹងនាំឲ្យមានការបាត់បង់ចំណូលថវិកាជាតិ ព្រោះថាសាច់ប្រាក់បានបង់ចូលបេឡារបស់រដ្ឋរួចហើយ។

**៤.១១. ការទូទាត់ និងការកត់ត្រាចំណាយ៖** ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិត្រូវបានកំណត់ឱសានវាទត្រឹមថ្ងៃទី៣១ ខែធ្នូនៃឆ្នាំសារពើពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិនៅតែមានភាពយឺតយ៉ាវ និងមិនទាន់សមស្រប ដូចជាអាណត្តិបើកប្រាក់មួយចំនួនដែលបាន បោះ

ផ្សាយរួចហើយពុំទាន់បានធ្វើការទូទាត់ និងកត់ត្រាចំណាយទាន់ពេលវេលា អាណត្តិបើកប្រាក់មួយចំនួនតែងតែបានបញ្ជូនទៅរតនាគារជាតិធ្វើការទូទាត់នៅក្រោយថ្ងៃឱសានវាទ បិទបញ្ជី ដែលបង្កឲ្យមានការកកស្ទះអាណត្តិបើកប្រាក់ និងលំបាកក្នុងការបូកសរុបបិទបញ្ជីប្រចាំឆ្នាំ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ជាទូទៅ អាណត្តិដែលបានបញ្ជូនចេញពីអគ្គនាយកដ្ឋានថវិកា ក៏ដូចជាពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើទៅតាមកាលបរិច្ឆេទកំណត់ (ត្រឹមថ្ងៃទី៣១ ខែធ្នូ នៃការិយបរិច្ឆេទ)។ ប៉ុន្តែនៅមានអាណត្តិមួយចំនួនតូច ដែលត្រូវការទូទាត់ចំណាយជាចាំបាច់ភ្ជាប់ជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ដោយប្រើប្រាស់ឥណទានដែលនៅសល់ក្នុងឆ្នាំ។

**៤.១២. ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ៖** សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែសម្រួលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋបានតម្រូវឲ្យគ្រប់ក្រសួងស្ថាប័ន និងសាលារាជធានីខេត្តធ្វើបញ្ជីសារពើភ័ណ្ឌលម្អិតសម្រាប់ឆ្នាំ២០០៤ ឲ្យបានជាដាច់ខាត ដើម្បីទុកជាឆ្នាំគោលសម្រាប់ការប្រៀបធៀបបញ្ជីសារពើភ័ណ្ឌឆ្នាំ២០០៥ និងនៅបណ្តាឆ្នាំចន្លោះ០៥ឆ្នាំស្តីពីការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនពុំបានអនុវត្តឲ្យបានពេញលេញតាមការតម្រូវខាងលើនេះទេ ដោយអង្គភាពមួយចំនួននៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌឆ្នាំគោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។

**៤.១៣. ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតែបានចេញលិខិត និងសារាចរណែនាំផ្សេងៗណែនាំឲ្យក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និងសាលារាជធានី ខេត្ត ដែលជាអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើអចលនទ្រព្យដែលបាននិងកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនឲ្យបានគ្រប់ចំនួន និងឆាប់រហ័សជាប្រយោជន៍ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១៣នេះ ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ បានបង្ហាញឲ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជា ធ្វើឲ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច **៧,៤%** លើសពីការព្យាករណ៍ដែលបានរំពឹងទុកក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ មានតែ **៧%** ប៉ុណ្ណោះ ព្រមទាំងសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក្នុងអាត្រាជាង**១%**ក្នុងមួយឆ្នាំ ដែលធ្វើឲ្យគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលសម្រេចបានមុនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានា បានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មគួរឲ្យស្ញើចសរសើរ ទោះបីចំណុចមួយចំនួននៅមិនទាន់ត្រូវបានអនុវត្តឲ្យប្រសើរនៅឡើយក៏ដោយ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្ម

ទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតទាំងនោះឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូល ចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា៖ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឲ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឲ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។